# ទីសំចត

ជីវិតលើវាលវដ្តសង្សារ
ដូចជនយាត្រាពនេចរ
ជួនជោគជតាវាសនាល្អ
ភប់ស្ថានបវរដ៏ប្រពៃ។
មានទីសំណាក់បានដាក់កាយ
សុខស្រួលសប្បាយឆ្ងាយទុក្ខភ័យ
សុខហើយកុំឡើយបង់ស្មារតី
សេពសោយដោយលៃបំផ្លាញផង។
កុំភ្លេចថារាល់រូបលោកអ្នក
គ្រាន់ជាអ្នកស្នាក់មួយកន្លង
ដល់កាលត្រូវចាកចេញទៅហោង
អ្នកក្រោយមកម្តងស្នាក់បន្ត។
តើគួរចេញទៅសល់នៅកេរ
ឱ្យអ្នកក្រោយជេរឬសាទរ?
បើមិនបន្សល់ផលល្អះល្អ
គួរកុំបង្កទុក្ខឱ្យគេ។
កើតមកជាមនុស្សទាំងប្រុសស្រី
ស្នាក់លើផែនដីមួយគ្រាទេ
បានទីចំណតចតល្ហើយល្ហែ
ចតហើយជួយថែកេរតអើយ៕

ប៊ុនចាន់ ជ័យរាជ អន័យសង្គ្រាម សុក្រសិរី

រូបភាព៖ **Ethan Crowley** - *www.ethancrowley.com*

